ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
លេខាធិការដ្ឋាន គ.ជ.អ.ប

លេខ ...៣០.....................

រាជធានីភ្នំពេញ ថ្ងៃទី..១៣..ខែ..ធ្នូ..ឆ្នាំ២០០៩

## ជម្រាបមក
## ឯកឧត្តមអភិបាលរាជធានី ខេត្ត
## និងជាប្រធានក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត

**កម្មវត្ថុ :** ការរៀបចំឡើងវិញនូវក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត និងការបង្កើតក្រុមគាំទ្រក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ។

**យោង :** -សេចក្តីសម្រេចលេខ ០១២ ស.ស.រ/ គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារគណនេយ្យភាពជាតិ

-សេចក្តីណែនាំលេខ ០១៤ ស.ណ.ន/គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្តីពីការរៀបចំកែសម្រួលនិងបង្កើតក្រុមការងារគណនេយ្យភាពខេត្ត ក្រុង ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមអភិបាលរាជធានី ខេត្ត និងជាប្រធានក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ជ្រាបថា ថ្មីៗនេះគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានដាក់ចេញ និងផ្ញើជូនដល់គ្រប់ខេត្ត ក្រុងទាំងអស់នូវសេចក្តីណែនាំលេខ ០១៤ ស.ណ.ន/គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការរៀបចំកែសម្រួល និងបង្កើតក្រុមការងារគណនេយ្យភាពខេត្ត ក្រុង ។ ដើម្បីពង្រឹងឡើងវិញនូវយន្តការរបស់ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សូមធ្វើការណែនាំដូចខាងក្រោម ÷

១- រាជធានី ខេត្ត ទាំងអស់ត្រូវធ្វើការប្រជុំផ្សព្វផ្សាយនូវសេចក្តីណែនាំខាងលើ ដល់អ្នកពាក់ព័ន្ធឱ្យបានទូលំទូលាយ ។

២- រៀបចំសមាសភាពក្រុមការងារគណនេយ្យភាពរាជធានី ខេត្តរបស់ខ្លួនឡើងវិញឱ្យស្របតាមសេចក្តីណែនាំថ្មីដែលបានដាក់ចេញដោយ គ.ជ.វ.វ ។

៣- រៀបចំក្រុមគាំទ្រដើម្បីជួយការងារដល់ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត។ សមាសភាព តួនាទី និងភារកិច្ចរបស់ក្រុមគាំទ្រត្រូវកំណត់ដាច់ដោយឡែកនៅក្នុងសេចក្តីសម្រេច ដែលចេញ ដោយក្រុមការងារគណនេយ្យភាពរាជធានី ខេត្តសាមី ។

៤- រាជធានី ខេត្តទាំងអស់ត្រូវធ្វើការជ្រើសរើសមន្ត្រីជំនួយការចំនួន ០១រូប ទៅ០៣រូប ផ្អែកតាមចំនួនដែលកំណត់ក្នុងបញ្ជីភ្ជាប់មកជាមួយដើម្បីជួយដល់ក្រុមគាំទ្រ ។ មន្ត្រីជំនួយការមិនមែនជាសមាជិក

ក្រុមគាំទ្រទេ។ មន្ត្រីជំនួយការដែលជ្រើសរើសត្រូវមានចំណេះដឹង បទពិសោធន៍ និងលក្ខណៈសម្បត្តិសមស្របតាមល័ក្ខខ័ណ្ឌដែលបានភ្ជាប់មកជាមួយ។ នីតិវិធីនៃការជ្រើសរើសមន្ត្រីជំនួយការរបស់ក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ត្រូវអនុវត្តតាមគោលការណ៍នៃការជ្រើសរើសបុគ្គលិករបស់គណៈកម្មាធិការប្រតិបត្តិនៃ គ.អ.ជ.ខ ដើម្បីធានាឱ្យមានតម្លាភាព និងប្រសិទ្ធភាព។

៥- ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការរៀបចំកែសម្រួលសមាសភាពក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត មកក្រុមការងារគណនេយ្យភាពជាតិតាមរយៈនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ។

សូមជូនភ្ជាប់មកជាមួយនូវបញ្ជីមន្ត្រីជំនួយការក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ដែលត្រូវជ្រើសរើសចំនួន ០១ច្បាប់ និងល័ក្ខខ័ណ្ឌការងារសម្រាប់មន្ត្រីជំនួយការក្រុមគាំទ្រចំនួន០១ច្បាប់។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមចាត់ចែងអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាព។

**លេខាធិការដ្ឋាន គ.ជ.អ.ប**

**ប្រធាន**

លេខ_ទី

**ចម្លងជូន :**

-សម័្ពន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ "សហការអនុវត្ត"

- ឯកសារ-កាលប្បវត្តិ